**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការធ្វើអនុបយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពី គោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពី វិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- លិខិតលេខ១២៧៦សជណ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ៥៤៣សជណ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ១០៨៤សជណ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ១១៩២សជណ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

www.pheakdeylaw.com

## សម្រេច

**មាត្រា១៖**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវ៖ - លើផ្ទៃដីទំហំ ៦ ១០៧,៥៥ ហិកតា (ប្រាំមួយពាន់មួយរយប្រាំពីរហិកតា ហាសិបប្រាំអារ) ដែលមានទីតាំងស្ថិតនៅក្នុងឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត របស់ក្រុមហ៊ុន វើលដ៍ ទ្រីស្តារ អ៊ិនធើណេសិនណល (ខេមបូឌា) សម្រាប់ឱ្យវិនិយោគដំណាំកសិ-ឧស្សាហកម្ម កសិកម្ម និងចិញ្ចឹមសត្វ ។ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច ដូចមានផែនទី និងនិយាមការលេខ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ របស់អភិបាលខេត្តកំពត ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

- លើផ្ទៃដីទំហំ ៧ ៨៩៦,១១ ហិកតា (ប្រាំពីរពាន់ ប្រាំបីរយកៅសិបប្រាំមួយហិកតា ដប់មួយអារ) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ របស់ក្រុមហ៊ុន ហ្វ្រេនឌីស ធីមប៊ើរ អិលធីឌី សម្រាប់ឱ្យវិនិយោគដាំដុះឈើម៉ៃសាក់ ។ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច ដូចមានផែនទី និងនិយាមការលេខ ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥ របស់អភិបាលខេត្តកំពង់ស្ពឺ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២៖**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តកំពត និងខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ [illegible] ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com